# កិច្ចសំភាសន៍របស់លោកយាយឈ្មោះ ទេព ម៉ាលីន

កៈ អ្នកសំភាសន៍ឈ្មោះ ហេង សុជីវី ខៈ អ្នកដែលត្រូវសំភាសន៍ឈ្មោះ ទេព ម៉ាលីន

កៈ ចាសជាដំបូងសូមជំរាបសួរលោកយាយ!

ខៈ ចាសជំរាបសួរចៅ! មានការអីដែរចៅ?

កៈ ចាសលោកយាយ! (មានសំលេងរំខានពីខាងក្រៅ) ថ្ងៃនេះផងដែរចៅមានឪកាសដើម្បីនឹងមកសំភាសន៍លោកយាយហើយចៅបានធ្វើការស្ម័គ្រចិត្តនៅក្នុងគំរោងរបស់សាលា BYU ហាវ៉ៃនៃសហរដ្ឋណាស់លោកយាយ!

ខៈ ចាសចៅ!

កៈ ហើយគំរោងរបស់សាលាមួយនឹងគេតម្រូវអោយធ្វើការសំភាសន៍ប្រជាជនកម្ពុជាដែលគាត់មានវ័យចាប់ពី ៣៥ឆ្នាំឡើងទៅអំពីខ្សែជីវិតពង្សប្រវត្តិរបស់គាត់អំពីបទពិសោធន៍ជីវិតរបស់ពួកគាត់ដើម្បីនឹងគេរៀបចំចងក្រងទុកជាឯកសារអោយកូនចៅជំនាន់ក្រោយនឹងគេបានស្តាប់ណាស់លោកយាយ! (មានសំលេងរំខានពីខាងក្រៅ)!

ខៈ ចាសចៅ!

កៈ ចាសលោកយាយ! អញ្ចឹងចៅមានឪកាសដើម្បីនឹងមកសំភាសន៍លោកយាយផ្ទាល់អញ្ចឹងតើលោកយាយអនុញ្ញាតអោយចៅធ្វើការថតសំលេងរបស់លោកយាយនឹងយករូបថតរបស់លោកយាយយកទៅផុសនៅក្នុងវេបសាយរបស់សាលាដែរឬទេលោកយាយ? (មានសំលេងរំខានពីខាងក្រៅ)!

ខៈ អត់អីទេបានតើចៅ! (មានសំលេងរំខានពីខាងក្រៅ)!

កៈ ចាសលោកយាយ! អញ្ចឹងអឺ....ជាដំបូងនៃការសំភាសន៍ថ្ងៃនេះគឺជាថ្ងៃទី១៩ ខែកក្កដា ឆ្នាំ ២០១៨!

ខៈ អឺម.....(មានសំលេងរំខានពីខាងក្រៅ)!

ក៖ ហើយចៅមានឈ្មោះថា ហេង សុជីវី គឺជាអ្នកសំភាសន៍លោកាយាយនៅថ្ងៃនេះផ្ទាល់តែម្តង!

ខ៖ អឹម.....ចាស! (មានសំលេងរំខានពីខាងក្រៅ)!

ក៖ ហើយជាមុនដំបូងនៃការសំភាសន៍ចៅសូមសួរឈ្មោះរបស់លោកយាយជាមុនសិនលោកយាយមានឈ្មោះអីដែរលោកយាយ?

ខ៖ ឈ្មោះនៅក្នុងនេះឈ្មោះ ទេព ម៉ាលីន ហើយចំណែកឈ្មោះហៅខាងក្រៅឈ្មោះស្រី! (មានសំលេងរំខានពីខាងក្រៅ)!

ក៖ អូ....លោកយាយឈ្មោះទេព ម៉ាលីនឹងគឺនៅក្នុងអត្តសញ្ញាណប័ណ្ណ.....

ខ៖ មិនមែនម៉ាលីទេ ម៉ាលីន ទេព ម៉ាលីន!

ក៖ ចាសលោកយាយ! ឈ្មោះនឹងត្រូវនឹងអត្តសញ្ញាណប័ណ្ណហ៎លោកយាយ?

ខ៖ ចាសៗឈ្មោះនៅក្នុងអត្តសញ្ញាណប័ណ្ណនឹងពេទ ម៉ាលីន ហើយនៅខាងក្រៅហៅថាស្រីអញ្ចឹងណាស់ចៅ!

ក៖ ចាសលោកយាយ!

ខ៖ នៅខាងក្រៅហៅ ម៉ាលីន អញ្ចឹងទៅណាស់!

ក៖ ទាំងនាមត្រកូលអីទាំងអស់នឹងហ៎លោកយាយ?

ខ៖ ចាសចៅ!

ក៖ ចុះឈ្មោះនឹងម៉េចក៏បានគេដាក់អោយលោកយាយអញ្ចឹងកាលនឹង?

ខ៖ ខ្ញុំអត់បានដឹងដែរចៅ ពីព្រោះអីឪពុកម្តាយអីរបស់ខ្ញុំនឹងគាត់ដាក់អោយពីដើមមកអញ្ចឹងណាស់ ដល់តែពេលដែលខ្ញុំចូលរៀនទៅគេដាក់នៅនឹងរៀនសូត្រគេហៅអញ្ចឹងទៅណាស់!

ក៖ ចាសលោកយាយ!

ខ៖ ដូចយើងពីឥលូវហៅទីមួយ ហើយបើដូចយើងពីដើមហៅថ្នាក់ទី១២អញ្ចឹងទៅណាស់!

កៈ ចាសលោកយាយ!

ខៈ ពេលដែលចូលរៀននឹងក៏ដាក់អញ្ចឹង!

កៈ អូៗ....ចាសលោកយាយ!

ខៈ ចាស! ចូលរៀនបានត្រឹមថ្នាក់ទីបីនឹងក៏ចូលដល់សម័យប៉ុលពត! (មានសំលេងរំខានពីខាងក្រៅ)!

កៈ គាត់អត់ទាន់ប្រាប់លោកយាយថាកាលនឹងអី....ហេតុអីបានជាគាត់ដាក់ឈ្មោះលោកយាយអញ្ចឹងទេន៍លោកយាយឪពុកម្ដាយរបស់លោកយាយណាស់?

ខៈ កាលនឹងគាត់អត់មានប្រាប់អីទេកាលនឹង! គ្រាន់តែថានៅពេលដែលចូលរៀនអញ្ចឹងគាត់ប្រាប់គាត់ដាក់ឈ្មោះនឹងទៅហើយគ្រូក៏គាត់ហៅតាមនឹងទៅណាស់! (មានសំលេងរំខានពីខាងក្រៅ)!

កៈ ចាសលោកយាយ!

ខៈ ចាសចៅ!

កៈ ចាសលោកយាយ! ហើយឥលូវនឹងលោកយាយមានអាយុប៉ុន្មានហើយលោកយាយ?

ខៈ ខ្ញុំអាយុ៦០ឆ្នាំហើយចៅ!

កៈ ហើយលោកយាយកើតនៅក្នុងឆ្នាំណាខែថ្ងៃណាដែរលោកយាយ?

ខៈ ខ្ញុំនឹងនៅឆ្នាំ១៩៥៨!

កៈ នៅក្នុងថ្ងៃខែណាលោកយាយ?(មានសំលេងរំខានពីខាងក្រៅ)!

ខៈ ខែទាល់តែមើលនៅក្នុងអត្តសញ្ញាណប័ណ្ណ!

កៈ អូ.....

ខៈ បើអត់បានមើលនៅក្នុងអត្តសញ្ញាណប័ណ្ណនឹងអត់ដឹងទេទាល់តែមើលនៅក្នុងអត្តសញ្ញាណប័ណ្ណអញ្ចឹងណាស់ចៅ!

កៈ ចុះលោកយាយមាន.....

ខ៖ តែពេលនេះខ្ញុំអត់មានយកមកជាប់នឹងខ្លួនទេណាស់ចៅ ខ្ញុំគ្រាន់តែដឹងថាខ្ញុំកើតនៅក្នុងឆ្នាំ១៩៥៨!

ក៖ ចាសលោកយាយ! ហើយសព្វថ្ងៃនឹងលោកយាយក្រុបកមុខរបរអីដែរលោកយាយ?

ខ៖ ធ្វើសៈធម៌នៅនឹងវត្ត ធ្វើបាសីអីអញ្ចឹងទៅណាស់ចៅ! (មានសំលេងរំខានពីខាងក្រៅ)!

ក៖ ប៉ុន្មានឆ្នាំដែរហើយលោកយាយ?

ខ៖ អឹម....ខ្ញុំធ្វើចង់ចូលជិតម្ភៃឆ្នាំជាងហើយចៅ ចាស!

ក៖ អូ....យូរណាស់ហើយន៍លោកយាយ?

ខ៖ ចាសចៅ!

ក៖ តាំងពីលោកយាយ.....

ខ៖ ខ្ញុំធ្វើតាំងពីកាលដែលនៅឆ្នាំ៩៣ (១៩៩៣)!

ក៖ តាំងពីឆ្នាំ៩៣(ឆ្នាំ១៩៩៣) មកណោះលោកយាយ!

ខ៖ នឹងហើយ៩៣(ឆ្នាំ១៩៩៣)!

ក៖ ចាសលោកយាយ! លោកយាយបានមកនៅនឹង អឺ...ហេតុអីក៏បានជាលោកយាយគិតថាចង់មកនៅនឹងវត្តនឹងហើយកាច់បាយសីបាយអីនឹង ណាស់លោកយាយ.....

ខ៖ មិនមែនខ្ញុំចង់មកនៅនឹងវត្តនឹងទេ កាលពីដើមឡើយនឹងខ្ញុំមានគ្រួសារអញ្ចឹងទៅហើយទៅគ្រួសាររបស់ខ្ញុំគាត់ពិការភ្នែកទាំងពីរអញ្ចឹងណាស់ទៅគាត់ទៅតាមម្តាយរបស់គាត់ទៅខាងជំរុំអញ្ចឹងទៅដល់ហើយទៅម្តាយធំរបស់ខ្ញុំនឹងយកខ្ញុំនឹងមកអោយនៅបំរើគាត់ ដល់តែអត់ពីម្តាយធំរបស់ខ្ញុំអញ្ចឹងឯងទៅគាត់ស្លាប់នៅក្នុងអាយុ៩០ឆ្នាំអញ្ចឹងណាស់ ដល់ពេលតែគាត់ស្លាប់បាត់ទៅខ្ញុំក៏នៅជាប់ធ្វើនឹងព្រះធម៌នឹងរហូតមកណាស់!

ក៖ ចាសលោកយាយ!

ខ៖ ចាសចៅ!

ក៖ អូ.....លោកយាយអញ្ចឹងបានជាអញ្ចឹងណាស់លោកយាយ!

ខ៖ ចាសហើយទៅខ្ញុំមានកូនពីរនាក់ អាមួយនឹងគេបានចប់បាក់ឌុបហើយបានអាមួយនឹងគេបានចង់មហា....មហាវិទ្យាល័យហើយអញ្ចឹងណាស់! (មានសំលេងរំខានពីខាងក្រៅ)!

ក៖ ចាសលោកយាយ!

ខ៖ ឆ្នាំទីបីណាស់!

ក៖ ចាសៗលោកយាយ!

ខ៖ រៀនខាង IT ណាស់ ហើយក៏លង់ទឹកស្លាប់បាត់ទៅ!

ក៖ អូ.....ហើយទៅលោកយាយមានកូននឹងទាំងអស់ប៉ុន្មាននាក់ដែរលោកយាយ?

ខ៖ ខ្ញុំមានកូនតែពីនាក់ទេថៅ!

ក៖ ស្រីប៉ុន្មានប្រុសប៉ុន្មាននាក់ដែរលោកយាយ?

ខ៖ ប្រុសទាំងពីរនាក់នឹងថៅ!

ក៖ ពូកគាត់មានឈ្មោះអីខ្លះទៅលោកយាយ?

ខ៖ បងគេនឹងឈ្មោះ មុល តុលា នៅធ្វើការអោយគេផលូវគេធ្វើការខាងអឺ....សន្តិសុខ ហើយអាប្អូនឹងស្លាប់បាត់ហើយស្លាប់ដោយសារតែលង់ទឹកនឹងស្លាប់នៅក្នុងអាយុ២៣ឆ្នាំនឹងណាស់ថៅ!(មានសំលេងរំខានពីខាងក្រៅ)!

ក៖ ចាសលោកយាយ! ហើយចុះសំរាប់ដូចជាប្តីរបស់លោកយាយវិញគាត់មានឈ្មោះអីដែរលោកយាយ?

ខ៖ គាត់ឈ្មោះ ទូច វុធ!

ក៖ គាត់ស្រុកកំណើតនៅឯណាដែរលោកយាយ?

ខ៖ គាត់ពីដើមឡើយនឹងស្រុកកំណើតរបស់គាត់នឹងនៅនឹងផ្សារដើមគរ!

ក៖ អឺម.....

ខ៖ តែគាត់នៃ....៥៨ឆ្នាំហើយ គាត់១៩៦០!

កៈ អឺម! ចាសលោកយាយ! គាត់នៅមានជីវិតនៅរស់នៅរហូតមកដល់សព្វថ្ងៃនឹងដែរឬទេលោកយាយ?

ខៈ នៅរាល់ថ្ងៃនឹងតើ ឥលូវនឹងគាត់ទៅផ្ទះវិញបាត់ហើយផ្ទះរបស់ខ្ញុំនឹងថ្នល់ទទឹងផ្លូវរទេះភ្លើងនៅតាមថ្នល់រទេះភ្លើងទៅ.....

កៈ ហ្អា....អញ្ចឹងទេ? លោកយាយទៅនឹងវត្តនេះចោលផ្ទះឯណោះទៅ?

ខៈ ខ្ញុំនៅនឹងវត្តតែពេលថ្ងៃនឹងទេ ខ្ញុំមកធ្វើបាសីរកស៊ីមកកាច់បាសីអោយគេអញ្ចឹងទៅណាស់ដល់តែពេលយប់ឡើងនឹងខ្ញុំទៅសំរាកនៅនឹងផ្ទះវិញ!

កៈ អូ....នៅពេលយប់នឹងក៏ទៅជួបជុំនឹងគ្រួសារវិញទៅហ៍លោកយាយ?

ខៈ ចាសគាត់មកនឹងនៅដែរពេលថ្ងៃឡើងនឹងគាត់មកជួយធ្វើបាសីយើងអញ្ចឹងទៅណាស់!

កៈ លោកតានឹង?

ខៈ ចាសចៅ!

កៈ ចុះលោកតាគាត់មានប្រកបមុខរបរអីដែរឬទេលោកយាយ? (មានសំលេងរំខានពីខាងក្រៅ)!

ខៈ គាត់មានមុខរបរអីសោះ គាត់អត់មានរកអីទេ រកតែយើងម្នាក់ឯងនឹងម៉ង!

កៈ អឺម! (មានសំលេងរំខានពីខាងក្រៅ)!

ខៈ គាត់ធ្វើការអត់កើតទេចៅ គាត់ពិការភ្នែកទាំងពីរនឹង!

កៈ អានេះវាជិតឈឹងហើយណាស់មើលលែងកើតហើយណាស់អាមួយចំហៀងនេះនឹងវាមើលទៅនឹងលែងឃើញអីហើយមើលទៅវាងងឹតឈឹងទៅហើយ ដល់តែម្ខាងនេះមើលឃើញព្រិលៗបាននៅអាចជិះកង់បាន គាត់នៅមើលឃើញបានខ្លះ បើដូចជាម្ហូបអញ្ចឹងយកមកដាក់អោយគាត់ហូបអញ្ចឹងទៅ!

កៈ លោកយាយកាច់បាសីអញ្ចឹងលោកយាយរកបានប្រាក់ចំណូលនឹងបានប៉ុន្មានដែរលោកយាយ?

ខ៖ បានវាអត់ទៀងទេថៅមុខរបរនឹងវាមិនមែនជារបរដែលយើងធ្វើប្រចាំថ្ងៃទេ វាទាល់តែមានគេរស់ទៅបានយើងធ្វើ នេះគាត់នេះ!
ក៖ ចាសៗ ចាសជំរាបសួរលោកតា(សើច)!

គ៖ បាទជំរាបសួរ!

ខ៖ អ៊ឹម! មើលភ្នែករបស់គាត់ហ៎!

គ៖ ថៅណាថៅណីកូនរបស់ខ្ញុំ.....

ក៖ អឺ....ថៅមកសំភាសន៍លោកយាយ លោកតា!

គ៖ អញ្ជឹង?

ក៖ ចាសលោកតា!

ខ៖ មើលសួរទៅគាត់ឆ្លើយទៅច្រងែងច្រងាងបន្តិចហើយ!

ក៖ (សើច) ចាសៗលោកយាយ អត់អីទេលោកយាយចាស!

ខ៖ ប៉ុន្តែគាត់អត់មែនអញ្ជឹងទៅណាស់ សំភាសន៍គាត់រៀងមានៈបន្តិច!

ក៖ ចាសលោកយាយ! ហើយចុះលោកយាយ!

គ៖ នែយាយវាអាហេងអត់ទាន់ទៅទេ? (លោកតាសួរលោកយាយ)!

ខ៖ គេទៅបាត់ហើយ! (លោកយាយឆ្លើយនឹងលោកតា)!

គ៖ ទៅបាត់ហើយ!

ខ៖ អ៊ឹម!

ក៖ ចាស!

ខ៖ គាត់សុំសំភាសន៍បន្តិច!

ក៖ ចាសលោកយាយ!

ខ៖ សួរទៅគាត់ភ្លេចច្រើនណាស់!

ក៖ ចាសលោកយាយ(សើច) ចាសអញ្ចឹងទាក់ទងជាមួយនឹងលោកយាយវិញអញ្ចឹងចៅសូមធ្វើការសួរបន្តហើយណាស់លោកយាយ?
អឺ....ទាក់ទងជាមួយនឹងការរៀបការនឹងលោកយាយមានអាយុប៉ុន្មានដែរលោកយាយ?

ខ៖ ចាស?

ក៖ កាលដែលលោកយាយរៀបការនៅក្នុងអាយុប៉ុន្មានឆ្នាំដែរលោកយាយ?

ខ៖ ខ្ញុំរៀបការនឹងខ្ញុំនៅអាយុ២៦ឆ្នាំ!

ក៖ អូ.....

ខ៖ ហើយឪវានឹងអាយុ ២៨ឆ្នាំ!

ក៖ អញ្ចឹងហ៎?

ខ៖ ចាស ខ្ញុំរៀបការនៅ៨៥(ឆ្នាំ១៩៨៥)!

ក៖ គាត់ប្អូនលោកយាយ!

ខ៖ ចាសប្អូនពីរឆ្នាំ!

ក៖ (សើច) ចុះលោកយាយ....

ខ៖ ខ្ញុំរៀបការនៅឆ្នាំ៨៥(ឆ្នាំ១៩៨៥)!

ក៖ ចាសលោកយាយ! កាលដែលលោកយាយពួកគាត់ជាអ្នករៀបចំទុកដាក់អោយឬក៏លោកយាយស្រលាញ់ដោយសារចិត្តរបស់ខ្លួនឯង?

ខ៖ យកដោយចិត្តរបស់ខ្លួនឯង ព្រោះខ្ញុំអត់មានឪពុកម្តាយទេខ្ញុំជាកូនកំព្រាអត់ម៉ែអត់ឪអត់បងអត់ប្អូនទាំងអស់ជីវិតរបស់ខ្ញុំតាំងពីអាពតនឹងមកខ្ញុំរស់នៅតែម្នាក់ឯងរហូត នៅនឹងខ្ទមដូចនែអឺ.....ខ្ទមមួយដែលនៅនឹងក្នុងភូមិរបស់គេអញ្ចឹងនឹងនៅនឹងខ្ទមនឹងតែឯងនឹងទៅ ចឹងណាស់ខ្ញុំអត់មានម៉ែឪទេ ម៉ែឪនឹងពួកគាត់ក៏បានស្លាប់ចោលអស់ទៅក៏ខ្ញុំមកនៅជាមួយនឹងម៉ែឪចិញ្ចឹមដែរមកនៅតាំងអឺ

តូចនឹងទៅមិនដឹងថាគេរើសយើងមកចិញ្ចឹមឬក៏សុំយកមកចិញ្ចឹមទៅក៏មិនដឹងទៅទេ ព្រោះកាលនឹងនៅនឹងជំនាន់ប៉ុលពតយើងម៉េចនឹងដឹង!

គ៖ ហេ! គេសំភាសន៏នឹងអង្គការឯណា?

ខ៖ (សើច) ឯងចេញមកច្រងាងអញ្ចឹង(សើច) អូយ....គាត់អត់សួរនេះទេ អត់ចេះទេ!

ក៖ (សើច) មិនអីទេលោកយាយ!

ខ៖ គាត់មិនសួរនិយាយអីសួរអញ្ចឹងឯងទៅក្រែងល មានគេស្គាល់!

ក៖ ចាសៗលោកយាយ! អឺ.....មិញចៅសុំសួរតណាស់លោកយាយ?

ខ៖ ចាសចៅ!

ក៖ មិញនឹងដល់អឺ.....លោកយាយស្រលាញ់គ្នាដោយចិត្តហើយន៏?

ខ៖ ចាសចៅ!

ក៖ ហើយអឺ....ឪពុកម្តាយរបស់លោកយាយកាលនឹងគាត់មានថាម៉េចដែរឬទេលោកយាយ?

ខ៖ អត់មានទេ ឪពុកម្តាយរបស់ខ្ញុំនឹងពួកគាត់ស្លាប់នៅក្នុងជំនាន់ប៉ុលពតនឹងទាំងអស់!

ក៖ ស្លាប់ទាំងអស់នៅក្នុងជំនាន់ប៉ុលពតនឹងហ៎លោកយាយ?

ខ៖ ឪពុក......

ក៖ លោកយាយមាននៅចាំឈ្មោះរបស់ពួកគាត់ដែរឬទេលោកយាយ?

ខ៖ ខ្ញុំនៅចាំតើ! ម្តាយរបស់ខ្ញុំស្លាប់តាំងពីខ្ញុំនៅអាយុ៥ឆ្នាំ ម្តាយចិញ្ចឹមទេណាស់មិនមែនម្តាយបង្កើតទេណាស់ បើម្តាយបង្កើតនឹងខ្ញុំអត់ដឹងទេចៅ!

ក៖ អញ្ចឹងហ៎លោកយាយ?

ខ៖ ខ្ញុំកើតមកមិនដឹងថាមុខរបស់ឪពុកម្តាយនឹងយ៉ាងម៉េចទេ ខ្ញុំដឹងត្រឹមតែថាដាច់ពីជំនាន់ប៉ុលពតនឹងខ្ញុំជាកូនកំព្រា!

ក៖ អូ.....លោកយាយដឹងតែថា.....

ខ៖ មានតែម្តាយមើល.....ម្តាយចិញ្ចឹមនឹងខ្ញុំបានអាយុបានប្រាំគាត់ក៏ស្លាប់បាត់ទៅ!

ក៖ អឺម.....

ខ៖ ហើយដល់ពេលដែលត្រូវជាឪពុកចិញ្ចឹមនឹងនៅក្នុងឆ្នាំ៧៦(ឆ្នាំ១៩៧៦)គាត់ក៏ស្លាប់ទៀតអញ្ចឹងហើយទៅក៏ខ្ញុំនៅរស់នៅតែឯងជាមួយនឹងបងរបស់គាត់បងរបស់ឪពុកម្ដាយចិញ្ចឹមនឹងទៀតគេរើសយកទៅចិញ្ចឹមតទៅទៀតអញ្ចឹងមក ដល់ពេលមកនៅនឹងនេះ....

ក៖ ចុះឪពុកម្ដាយចិញ្ចឹមរបស់លោកយាយនឹងគាត់មានឈ្មោះអីដែរលោកយាយ?

ខ៖ ឪពុកៗចិញ្ចឹមគាត់ឈ្មោះ ទេព អៀង ហើយម្ដាយឈ្មោះ នួន ម៉ាលីស ម្ដាយចិញ្ចឹមរបស់ខ្ញុំនឹងណាស់ ចាសដឹងខ្ញុំបានដឹងតែប៉ុណ្ណឹងតែគ្រាន់តែថាកាលនឹងខ្ញុំទើបតែបានអាយុប្រាំឆ្នាំខ្ញុំនៅមិនទាន់បានដឹងអីមែនទែនទេណាស់!

ក៖ ចាសលោកយាយ (មានសំលេងរំខានពីខាងក្រៅ)!

ខ៖ ហើយទៅគាត់ក៏បានស្លាប់បាត់ទៅ ហើយទៅគាត់ក៏បានទុកខ្ញុំនឹងតែម្នាក់ឯងនឹងទៅ!

ក៖ គាត់ស្លាប់ទាំងពីរនឹងតែម្ដងហ៎លោកយាយ?

ខ៖ នឹងហើយឪពុកស្លាប់នៅនឹងជំនាន់ប៉ុលពត៧៦(ឆ្នាំ១៩៧៦) ម្ដាយចិញ្ចឹមរបស់ខ្ញុំនឹងស្លាប់តាំងពីនៅអាយុប្រាំតាំងពីខ្ញុំនៅស្ទើរដែរនឹង!

ក៖ ចុះអឺ....កាលដែលលោកយាយនៅជាក្មេងកំព្រានឹងលោកយាយនៅនឹងឯណាដែរ? នៅនឹងស្រុក.....ស្រុកអីដែរ?

ខ៖ ស្រុកនៅនឹងស្រុក....នៅខាងស្រុករបស់ឪពុកចិញ្ចឹមព្រោះនៅខាងឪពុកចិញ្ចឹមណាស់ នៅនឹងបែកចានយើងនឹងចុះពីផ្សារបែកចាននឹងទៅបន្តិចនឹងនៅភូមិអំពិល(មានសំលេងរំខានពីខាងក្រៅ)!

ក៖ អញ្ចឹងមានន័យថាតាំងពីលោកយាយដឹងក្ដីនឹងមកគឺលោកយាយនៅជាមួយនឹងឪពុកម្ដាយចិញ្ចឹមនឹងម៉ង?

ខ៖ នឹងហើយចៅ! ហើយអត់ដឹងថាខ្លួនឯងនឹងគឺជាកូនចិញ្ចឹមទេទាល់តែគាត់ស្លាប់នឹងក៏គាត់អត់ប្រាប់យើងទៀត!

ក៖ អូ.....

ខ៖ អត់ប្រាប់ថាអូ....នៃឥលូវនឹងអាញជិតស្លាប់ទៅហើយអាញប្រាប់ការពិតណាស់ ដូចអ្នកខ្លះគេប្រាប់យើងអោយដឹងហើយណាស់ មកដឹងនឹងបងរបស់គាត់ដែលខ្ញុំមករស់នៅជាមួយនឹងទេ!

ក៖ អូ.....គាត់ប្រាប់ហ៎លោកយាយ?

ខ៖ ចាសគាត់ប្រាប់! សុំនឹងក៏មិនដឹងថាគាត់សុំយកមកពីណាដែរ!

ក៖ អឺម....

ខ៖ គ្រាន់តែដឹងថាគាត់សុំពីគេសុំនៅកំពង់ត្រឡាច ការពិតម្ដាយធំរបស់ខ្ញុំនៅខាងឪពុកចិញ្ចឹមនឹងគាត់ជំណើរអ្នករត់ជំណើររត់ទូកដ នៅកំពង់ត្រឡាចកំពង់ឆ្នាំងអីអញ្ចឹងណាស់អញ្ចឹងសុំខ្ញុំនៅនឹងកំពង់ឆ្នាំងនឹងមក ហើយទៅយើងក៏មិនប្រាកដថាយើងជាកូនដែលគាត់សុំឬក៏កូនដែលគាត់រើសយកមកចិញ្ចឹមគឺ យើងអត់ដឹងទេ នៅជាមួយនឹងឪពុកនឹងទាល់តែយើងអាយុ១៥ឆ្នាំ ១៦ឆ្នាំនឹងយើងមិនចូលដល់ជំនាន់អាពត ហើយនៅអាយុ១៦ឆ្នាំ ១៧ឆ្នាំនឹងក៏ឪពុកចិញ្ចឹមនឹងក៏គាត់ស្លាប់ទៅទៀត យើងនៅតែមិនដឹង(មានសំលេងរំខានពីខាងក្រៅ) នៅជាមួយនឹងគេរហូតមក(មានសំលេងរំខានពីខាងក្រៅ)!

ក៖ ចាសលោកយាយ! ចុះកាលនឹងបងប្អូនរបស់លោកយាយមានប៉ុន្មាននាក់ដែរលោកយាយ? បងប្អូន.....

ខ៖ អត់មានទេ!

ក៖ បងប្អូនអត់មានទៀត?

ខ៖ អត់មានទេ!

ក៖ ហើយចុះអឺ.....

ខ៖ ឪពុកម្ដាយចិញ្ចឹមនឹងក៏អត់មានកូនដែរ!

ក៖ អូ....ចុះបងស្រីដែលប្រាប់រឿងពិតដល់លោកយាយនោះដែលគាត់ប្រាប់លោកយាយថាលោកយាយគឺជាកូនចិញ្ចឹមនោះគាត់ក៏អត់មានកូនដែរ?

ខ៖ នឹងនិយាយៗខាងបងរបស់គាត់តើ! បងស្រីរបស់ឪពុកចិញ្ចឹមនឹងគាត់ប្រាប់!

ក៖ អូ.....ចាសលោកយាយ!

ខ៖ ដល់តែពេលដែលគាត់ស្លាប់នឹងទៅគាត់មានពីរនាក់បងប្អូនបង្កើតអញ្ចឹងណាស់ បងរបស់ខាងប្រពន្ធរបស់គាត់នឹងគាត់ស្លាប់បាត់ទៅ ដល់ហើយទៅនៅបងរបស់គាត់បង្កើតនឹងគាត់ប្រាប់ ខ្ញុំ.....គាត់ក៏មិនចង់ប្រាប់ដែរក៏ប៉ុន្តែខ្ញុំសួរដូចថាទៅអាពតអញ្ចឹងដូចថាយើងថាទៅ.....

គ៖ នេះកូនញុំទឹកមួយដងសិនទៅ!

ក៖ ចាសអរគុណលោកតា អរគុណច្រើន អឺម! លោកតាចិត្តល្អណាស់!

ខ៖ ចិត្តល្អណាស់ទេ ប៉ុន្តែទាស់តែថាច្រងែងច្រងាង ចេះនិយាយស្រួល!

ក៖ (សើច)!

ខ៖ (សើច) ចេះនិយាយស្រួល (មានសំលេងរំខានពីខាងក្រៅ) អញ្ចឹងបើត្រូវគាត់និយាយទាំងច្រឡោតទោងតាងនឹង!

ក៖ ចាសៗលោកយាយចាស!

ខ៖ វាអត់.....

ក៖ ចុះលោកយាយកាលជំនាន់ប៉ុលពតនឹងគេ....គេជំលៀសលោកយាយទៅណាដែរលោកយាយមាននៅចាំដែរឬទេ?

ខ៖ ទៅនែ.....នេះទៅខាងក្រៅព្រែកក្មេងជាំសៅកែបត់សែតាភ្លុកនេះ!

ក៖ អ៍.....

ខ៖ នែ....ស្រុក៥១ តំបន់៣៣ ទៅពត ខ្ញុំមុនដំបូងនឹងទៅដល់ជាំសៅកែ ហើយទៅបានទៅព្រែកក្មេង ចេញពី....ចេញពីជាំសៅកែមកដល់ព្រែកក្មេងអញ្ចឹងណាស់ចៅ!

ក៖ ចុះគេប្រើលោកយាយធ្វើអីដែលកាលនឹងណាស់លោកយាយ?

ខ៖ ខ្ញុំអឺ....ធ្វើជាកងចល័ត....កងចល័តឃុំព្រោះអីអោយតែពេលអាពតវាមិនយកទៅវ៉ៃចោលផងវាដូចថាចេះតែមានអីតាមជួយថៃរក្សាយើងអញ្ចឹងណាស់យើងជឿរទៅលើជំនឿអបិយជំនឿរអញ្ចឹងណាស់ឧបមានថាឥលូវនឹងគេត្រូវទៅតាមតំបន់អ៊ឹម....

ក៖ អ៊ឹម....

ខ៖ មួយកងស្រួចគេនោះហើយទៅថ្ងៃនឹងរៀបចំខោអាវត្រូវទៅតាមកងស្រួចនឹងហើយស្រាប់តែយប់ឡើងនឹងឈឺបើមិនអញ្ចឹងពស់ចឹកបើមិនអញ្ចឹងទេក្អែបខាំ!

ក៖ អ៊ឹម! មានពស់ចឹកទៀត?

ខ៖ អ៊ឹម? ចឹកជើងណាស់នាងមិនទាន់បានទេ!

ក៖ អូ....ពស់អីដែលចឹកនឹងលោកយាយ?

ខ៖ ក្អែបខាំ! យើងមិនដឹងថាពស់អីទេកាលនឹងណាស់ជូនណាទៅយើងវែកដីទំនប់វែកអីអញ្ចឹងដល់ហើយទៅកាយចំអាពស់ត្បាលពស់អីគេនឹងមូលៗនោះ!

ក៖ អូ.....ស្រៀវណាស់លោកយាយដល់អញ្ចឹងអី(សើច)!

ខ៖ អ៊ឹម....ជូនណាទៅក្នុងនឹង....យើងទៅដីអញ្ចឹងហើយដាក់បង្គីអញ្ចឹង....អើដូចថាយើងវាអស់កំលាំងណាស់ហើយទៅក៏ដាក់បង្គីអញ្ចឹងស្រាប់ពស់នឹងវារចូលទៅក្នុងបង្គីនឹងនៅនឹងក្បែរយើងនឹងក៏មានដែរ!

ក៖ អូហូ....

ខ៖ ដូចបុណ្យរបស់យើង....យើងនិយាយថាបុណ្យជួយយើងទៅវាមិនត្រូវងាប់! វែក....វែកដីវែកអី....

ក៖ ហើយជួបពស់ទៀតទៅហ៎លោកយាយ?

ខ៖ ចាស?

ក៖ នៅពេលដែលពស់ចឹកជើងរបស់យើងអញ្ចឹងគេអោយយើងឈប់ដែរឬទេលោកយាយ?

ខ៖ គេអោយយើងទៅពេទ្យក៏ប៉ុន្តែថ្នាំអីនឹងវាមិនដូចជាយើងសម័យនេះទេ ថ្នាំនឹងដូចនឹងអាចមិទន្សាយអាចមិអីនឹង!

ក៖ អឺម!

ខ៖ ក្អែបខាំអញ្ចឹងគេអោយយើងផឹកស្លែងដងដឹងជាមួយនឹងអាស្លែងពុល....ពុលស្លាប់ណាស់!

ក៖ ចាសលោកយាយ!

ខ៖ ផ្លែស្លែងដងដឹងនឹងឯងយកទៅដុសជាមួយនឹងទឹកអង្ករ!

ក៖ អឺម!

ខ៖ ហើយនឹងគ្រាប់ក្រូចសើចហើយយើងផឹកហើយទៅយើងសន្លប់បាត់ហើយនឹង(មានសំលេងរំខានពីខាងក្រៅ) ផឹកហើយសន្លប់បាត់ ចាសពិសវាបង្រ្កាបពស់ផងទៅក៏មានដឹងយើងវាមិនដឹងដែរ!

ក៖ សន្លប់ទៅក៏នៅពេលដែលដឹងខ្លួនឡើងអត់អី(សើច)!

ខ៖ គេយកយើងទៅពេទ្យនឹងទៅដឹងខ្លួននៅនឹងពេទ្យ!

ក៖ (សើច) អូ....

ខ៖ មានស្អីថៅអើយ! បើយកទៅពេទ្យដល់ពេលដែលយើងសន្លប់នឹងឯងគេសែងយកយើងទៅពេទ្យនឹងឯងទៅវាហើយថ្នាំវានឹងអាចមិ....ដូចថាកិតអាដែងនែ(ភាសាតំបន់) ឧទាហរណ៍ថាជាក្បាលអញ្ចឹងជាក្បាលដំលូវមីក្រូចឆ្មាអីនឹងគេនេះទៅ!

ក៖ ចាសលោកយាយ!

ខ៖ រួចបើថានេះវិញគេពុះឡាំងអញ្ចឹងនឹងគេដាក់គ្រាប់ស្លែងនឹងដាក់កម្លោចនឹងស្អីទៅធ្វើជាសំបកបន្ទសវាណាស់នឹងគេធ្វើដូចថាគេមានពុម្ពរបស់គេអញ្ចឹងទៅនៅពេលដែលគេបាញ់ថ្នាំដែលគេធ្វើនឹងចេញមកវាចេញជារៀងមូលចឹងមក!

ក៖ អូ....

ខ៖ អានឹងគេហៅថាថ្នាំអាចមិទន្សាយថ្នាំឧសថបុរាណអញ្ចឹងណាស់ចៅ ប៉ុន្តែគ្រាន់តែថាវាអត់ធំទេប៉ុនៗនេះ!

ក៖ អូ....

ខ៖ ប៉ុននឹង ហើយជូនណាទៅមានពីរគ្រាប់ ហើយបើខ្ញុំស្រវឹងអឺ....ថ្នាំស្លែងនឹងគេអោយលេបនោះហើយទៅយើងកំលាំងនៅខ្សោយនោះ ដើរអញ្ចឹងឯងទៅៗស្ទួងទៅច្រូតអញ្ចឹងឯងទៅយើងស្រវឹងថ្នាំស្លែងនោះដូចយើងស្រវឹងស្រាអញ្ចឹងណាស់!

ក៖ អឺម!

ខ៖ ដើរទៅធ្លាក់ទឹកព្រោង!

ក៖ អឺស!

ខ៖ ចុះបើយើងពុលអាថ្នាំស្លែងគេនោះ យើងកំលាំងរបស់យើងនឹងរត់អត់រួចនឹងថ្នាំនឹង!

ក៖ ចុះប៉ុន្មានថ្ងៃបានលោកយាយដឹងខ្លួនធម្មតាវិញ?

ខ៖ អត់ទេទៅតែមួយឆាវនឹងទេ ដល់តែយើងបត់ជើងតូចបត់ជើងធំទៅវាធម្មតាវិញហើយអញ្ចឹងណាស់!

ក៖ អញ្ចឹង?

ខ៖ អឺម! នឹងកាលជំនាន់ប៉ុលពតណាស់ចៅ!

ក៖ នឹងកាលនឹងគេដាក់តិចផង បើគេដាក់ច្រើននឹងលោកយាយមិននេះទេ!

ខ៖ កាលនឹងមិនដឹងថាគេលាយថ្នាំស្អីៗខ្លះទេ ព្រោះអីយើងបើយើងនិយាយទៅយើងវាអត់មានអីហូបផងហើយអត់មានមកទៀត(មករដូវ)!

ក៖ អត់មានមកទៀតហ៎លោកយាយ?

ខ៖ អត់មានមកទេ ព្រោះយើងបើធម្មតាតែ១៦ឆ្នាំយើងមិនត្រូវគ្រប់ការហើយណាស់!

ក៖ ចាសលោកយាយ!

ខ៖
តែយាយវិញទម្រាំតែគ្រប់ការទាល់តែអាយុ១៩ឆ្នាំឯណោះហើយទៅដូចជាមនុស្សប្រុសអញ្ចឹង
!

ក៖ អឺម!

ខ៖ ងាកឈឺតិចឈឺៗៗអញ្ចឹងហើយកំលាំងយើងបើគ្មានអានឹងទេវាអត់ស្រួលទេ ព្រោះបើយើងរាំងពេលអញ្ចឹងរាំងយើងមិនមានកំលាំងឯណានឹងធ្វើការណាស់ចៅណាស់!

ក៖ ចាសលោកយាយ!

ខ៖ ហើយបើយើងឈឺអញ្ចឹងគេគៀរអាពពុះបបរដែលអណ្តែតនៅនឹងលើនឹងអោយយើងហូប!

ក៖ អឺម!

ខ៖ ហើយនៅពេលដែលយើងឈឺអញ្ចឹងនឹងគេចាប់ឡើងគេចោទសួរយើងថា តើអ្នកនឹងឈឺសតិអារម្មណ៍ឬក៏ឈឺពិត? (មានសំលេងរំខានពីខាងក្រៅ)!

ក៖ អឺម!

ខ៖ ហើយទៅបើសិនជាយើងនៅទ្រាំបានយើងគេអោយយើងនឹងទៅធ្វើការទៀតទៅ!

ក៖ ឈឺអីគេខ្លះទៅលោកយាយកាលនឹង?

ខ៖ ឈឺអីគ្រុនរងារនឹងណាស់ចៅ! ភាគច្រើននៅខាងខ្ញុំគ្រុនញាក់នៅនឹងមានភ្នំព័ន្ធជុំវិញអញ្ចឹងណាស់(មានសំលេងរំខានពីខាង
ក្រៅ)
ដល់អញ្ចឹងទៅវាអាចមកពីដើមឈើនឹងច្រើនឬក៏អាចមកពីស្លឹកឈើនឹងវាជ្រុះច្រើនពេកបណ្តាលអោយទៅជាគ្រុនចាញ់ក៏ថាបាន!

ក៖ អឺម!

ខ៖
ហើយបើតាមទឹកដែលហូរនឹងក៏វារលួយស្លឹកឈើទាំងអស់នឹងទៅក៏ថាបាន(មានសំលេងរំខានពីខាងក្រៅ) ភាគច្រើននឹងគឺគ្រុនញាក់នឹងម៉ង!

ក៖ អញ្ចឹងហ៎លោកយាយ?

ខ៖ នឹងហើយចៅ! នៅមួយស្រុកខ្ញុំនៅនឹងខេត្តកំពង់ស្ពឺនឹងភាគច្រើននឹងគឺគ្រុនញាក់នឹងម៉ង!

ក៖ អូ......

ខ៖ បើខ្ញុំវិញគ្រុនញាក់មួយថ្ងៃនឹងបីដង(មានសំលេងរំខានពីខាងក្រៅ)!

ក៖ អឺស!

ខ៖ ញាក់ក្តៅ....ញាក់ក្តៅជូនណាទៅរៀងអន់ហើយនឹងញាក់ពីរដងនឹង គឺថាគ្រុនញាក់ខ្លាំងម៉ងឯងខ្ញុំញាក់នឹងខ្លាំងជាងគេ(មានសំលេងរំខានពីខាងក្រៅ) ដល់តែពេលដែលជានឹងដឹងជានឹងអីទេ?(សើច) ជានឹងឬសអំពិលពូនដំបូកជាមួយនឹងកន្ទុកយើងនឹង!

ក៖ ឬសអំពិលដើមអំពិលហ៎លោកយាយ?

ខ៖ ដើមអំពិល!

ក៖ អំពិល.....

ខ៖ នឹងដើមអំពិលផ្លែយើងនឹង

ក៖ ដែលយើងយកមកស្លរនឹងហ៎លោកយាយ?

ខ៖ អើ! នឹងហើយ អានឹងគេថាសាច់ណាស់ចៅ អាដែងនៃ(ភាសាតំបន់) ច្រើនតែហើមសាច់ព្រោះអីយើងអត់មានប្រៃដល់តែនេះទៅវាទៅជាហើមសាច់ណាស់ចៅ!

ក៖ ចាសត្រូវហើយលោកយាយ!

ខ៖ ដល់តែហើមខ្ញុំគេអោយហូបអាំងអឺ....កាលជំនាន់ប៉ុលពតនឹងឯងគេអោយខ្ញុំហូបកន្ទុកជាមួយនឹងអឺ....ស្លរត្នោតអូ...បានអានឹងមិនបាច់ទេឈ្ងុញ់លើសបាយទៅទៀតន៏!

ក៖ អឺម.....

ខ៖ ចាសខ្ញុំគេអោយហូបអានឹងណាស់កន្ទុកលាយជាមួយនឹងស្លរនឹងឯងទៅដូចក្លូរបាយត្រៀបយើងអញ្ជឹងណាស់ យើងគ្រាន់តែយកវាមកក្លូរជាមួយនឹងស្លរនឹងឯងទៅ!

កៈ ចាសលោកយាយ!

ខៈ ហើយទៅគេអោយយើងនឹងហូបអានឹង! គេអោយយើងហូបអានឹងឯងទៅ(ហូបកន្ទុកកូនលាយជាមួយស្ករ) ហើយផឹកជាមួយនឹងឫសដើមអំពិលឫសវល្លិថ្មឹងយើងណាស់!

កៈ អ៊ឺម....

ខៈ ចៅឯងស្គាល់ដែរទេ? ស្លឹកថ្មឹងយើងដែលយើងចំណាំយកមកស្លម្ជូរគ្រឿងណាស់!

កៈ ខ្ញុំស្គាល់ស្លឹកថ្មឹងនោះតែឫសវាខ្ញុំអត់ស្គាល់ផង!

ខៈ នឹងហើយអាវល្លិរបស់វានឹង!

កៈ ចាសលោកយាយ!

ខៈ ដើមវាយើងនេះទៅ(មានសំលេងរំខានពីខាងក្រៅ) យើងយកឫសរបស់វាមកដាំហូបហើយដើមនឹងដុះនៅលើកន្លែងដែលកន្ទៀវវាពូនជាដំបូក ដូចថាយើងវាអត់មានស្អីហូបទេដល់ពេលហើយគេអោយយើងហូបអានឹងព្រោះយើងហូបវាអត់គ្រប់គ្រាន់!

កៈ ម៉េចវិញលោកយាយ អានឹងសំរាប់គេយកពេលដែលពស់ចឹងអីនឹងឬក៏ម៉េច?

ខៈ មិនមែនទេចៅ! អានឹងសំរាប់ពេលដែលយើងហើមខ្លួន!

កៈ នៅពេលដែលហើមខ្លួនបានគេអោយលោកយាយហូប?

ខៈ នឹងហើយនៅពេលដែលយើងហើមគេអោយ.....

កៈ គេអោយលោកយាយហូបអានឹង!

ខៈ នឹងហើយគេអោយយើងហូបអានឹង!

កៈ គេអោយផឹកអានឹងហ៎ដាំទឹកផឹកហ៎លោកយាយ?

ខៈ នឹងហើយដូចថាគេឃើញយើងហើមខ្លួនអញ្ចឹងទៅណាស់នឹងហើយខាងមូលដ្ឋានគេអោយយើង នឹងហើយដល់អញ្ចឹងទៅខាងមូលដ្ឋានគេអោយយើងហូបអានឹង!

កៈ ដាំទឹកមួយយកទឹកពីរអញ្ចឹងទៅ?

ខៈ ដាំទឹកមួយយកទឹកបីអ៎....ដាំទឹកបីយកទឹកមួយព្រោះយើងដាំ(មានសំលេងរំខានពីខាងក្រៅ) ដូចថាយើងដាំទឹកនឹងបីកែវរម្ងាស់វាអោយនៅតែទឹកមួយកែវទៅនឹងគេហៅទឹកមួយអ៎....ទឹកបីយកទឹកមួយហើយ!

កៈ អឹម.....

ខៈ ទាល់តែជ័រនឹងចេញទាល់តែអស់ម៉ងណាស់!

កៈ អឹម.....អញ្ចឹងៗមិញនឹងមានដើមថ្នឹងហើយឬសរបស់វានឹងហើយនឹងជាមួយនឹងកន្ទុកហើយទៅដើមអំពិល.....

ខៈ ហើយអានឹងយើមកដាំទឹកហូបទៅហើយកន្ទុកនឹងកូរស្ករយើងមកហូបធម្មតាតិចៗនឹងទេប៉ុនៗមេដៃអីទេ!

កៈ ហូបប៉ុនៗមេដៃ?

ខៈ អឹម....

កៈ លុញ់ៗវានឹងទៅ!

ខៈ អឹមលុញ់ៗវាទៅក៏ហូបខ្លួនឯងនឹងទៅ!

កៈ អឹម! កាលនឹងមានថ្នាំធម្មជាតិន៍លោកយាយ?

ខៈ នឹងបានថ្នាំធម្មជាតិនឹងមានតែថ្នាំធម្មជាតិនឹងហើយជំនាន់ប៉ុលពតបានអីហូបថៅតែគេប្រាប់អាណាហូបអានឹងហើយ!

កៈ ចាសលោកយាយ! ហើយចុះបើសត្វក្អែបខាំអីនឹងគេធ្វើម៉េចវិញលោកយាយ?

ខៈ បើសិនជាក្អែបខាំពស់ចឹកអីនឹងគេ....ខ្ញុំអត់ដឹងទេប៉ុន្តែគ្រាន់តែថាពេលដែលខ្ញុំសន្លប់នឹងហើយពេលដឹងខ្លួនវិញគេប្រាប់ថាស្លែងដងដឹងជាមួយក្រូចសើចគ្រាប់ក្រូចសើចដុសជាមួយនឹងទឹកអង្ករនឹងៗនៅពេលដែលខ្ញុំដឹងខ្លួនឡើងគេហូបអានឹង!

កះ ហើយទៅគេអោយលោកយាយហូបមានកែវអញ្ចឹងទៅ!

ខះ អើ! ប្រហែលជាប្រវែងនេះនឹងឯងថៅ គេមិនអោយយើងដល់មួយកែវទេតែបន្តិចនឹងទេ!

កះ បន្តិតនឹង!

ខះ នឹងអាស្លែងនឹងខ្លាំងណាស់ពុលស្លាប់ណាស់! ចុះបើមើលយើងផឹកអានឹងហើយសន្លប់បាត់ហើយនឹង!

កះ (សើច)!

ខះ ហើយទៅយើងដឹងឡើងនៅនឹងពេទ្យឯណោះ!

កះ ចាសលោកយាយ!

ខះ ពេទ្យអាពតនឹង!

កះ (សើច) អូ....ពេទ្យគេប្រាប់លោកយាយដែរន៏ថាគេដាក់.....

ខះ នឹងហើយគេប្រាប់!

កះ ថាគេដាក់ស្លែងបន្តិចហើយនឹងគ្រាប់ក្រូចសើច!

ខះ នឹងដឹងហើយដឹងតាំងពីយើងនឹងមិនទាន់នឹងសន្លប់ ហើយទៅគេដុសអោយហូបហើយនឹងណាស់ខាងមូលដ្ឋានគេដុសអោយយើងហូប!

កះ អូ....គេដុសនៅនឹងមុនលោកយាយម៉ង!

ខះ នឹងគេដុសនឹងគំរបឆ្នាំងដីនឹង!

កះ អញ្ចឹង?

ខះ នឹងហើយដុសវាដាក់ទឹកបន្តិចៗទៅដាក់ទឹកអង្ករនឹងទៅ(មានសំលេងរំខានពីខាងក្រៅ) ដុសរួចហើយគេអោយយើងនឹងហូប
ដល់តែពេលហូបហើយសន្លប់ហើយបានហូរតាមជើងរបស់យើងនឹង(មករដូវ)!

កះ អឺម! ដល់ពេលដែលមកវិញអត់អី!

ខះ នឹងហើយ!

កៈ អញ្ចឹងពេទ្យកាលនឹងពូកែរបស់គេន៍លោកយាយ?

ខៈ ចាសចៅ! (មានសំលេងរំខានពីខាងក្រៅ)!

កៈ ចុះលោកយាយកាលនឹងលោកយាយដែលបានឃើញប៉ុលពតយកមកមនុស្សទៅសម្លាប់ចោលដែរឬទេលោកយាយ?

ខៈ ខ្ញុំអត់ដែលបានឃើញផ្ទាល់នឹងភ្នែកនឹងទេ គ្រាន់តែថាពេលដែលគេសម្លាប់មនុស្សអីអញ្ចឹងទៅគេចាក់មេក្រូមេអីអញ្ចឹងទៅបន្លំមិនអោយយើងដឹងអញ្ចឹងណាស់!

កៈ អូ.....

ខៈ ឃើញបណ្តើរទៅអញ្ចឹងនឹងយើងបានឃើញណាស់កូន (មានសំលេងរំខានពីខាងក្រៅ) តែនៅពេលដែលគេសម្លាប់ចោលនឹងគេមិនអោយយើងឃើញទេកូន ព្រោះផ្លូវអញ្ចឹងអ្នកខាងនេះនៅខាងនេះ ហើយអ្នកខាងណោះនៅខាងណោះ អត់មានអ្នកណាដឹងពីរឿងនឹងនោះទេ!

កៈ អឹម! ចាសលោកយាយ! ហើយដល់ពេលអញ្ចឹងលោកយាយគេបង្អត់បាយបង្អត់អីដូចថាយើងញុំអត់គ្រាប់គ្រាន់អីអញ្ចឹងនឹងលោកយាយធ្លាប់មានដែរឬទេលោកយាយ?

ខៈ ធ្លាប់ចៅ!

កៈ ហើយគេអោយបបរអីប៉ុន្មានពេលដែលលោកយាយ?

ខៈ ខាងខ្ញុំនឹងពិបាកណាស់....ពិបាកណាស់ បើគេអោយហូបបាយអញ្ចឹងគេដាំបាយចំហុយអញ្ចឹងគេដាក់បាយមួយគ្រាប់ៗអញ្ចឹងឯងទៅហើយទៅគេដាក់ពោតក្រហមយើងនឹង!

កៈ អូ....

ខៈ គេស្ងោរពោតក្រហមនឹងលាយជាមួយនឹងបាយអញ្ចឹងទៅហើយយកទៅដាក់នឹងសឹងគេចំហុយទៅនឹងគេថាបាយចំហុយគេហើយនឹង

ជូនណាទៅគេលាយបាយមួយគ្រាប់ៗនឹងលាយជាមួយនឹងដុំដំលូងមីខាងខ្ញុំនឹងពិបាកណាស់ គេដាក់លាយនឹងដំលូវមីព្រោះនៅនឹងភ្នុំនឹងគេដាក់ដាំដំលូវមីប៉ុនៗនេះ!

ក៖ ចាសលោកយាយ!

ខ៖ ដល់អញ្ចឹងគេយកដំលូវមីដំលូវជ្វានឹងយកមកលាយជាមួយនឹងបាយ!

ក៖ អឹម.....

ខ៖ រួចបាយជាមួយនឹងដំលូវមីដំលូវជ្វានឹងណាស់ហូបហើយ ជូនណាទៅមានបាយគល់ល្ហុងកាលដែលនៅជំនាន់ប៉ុលពតនឹងឆ្លងកាត់អស់ហើយធ្លាប់ហូបអស់ហើយចៅអើយ!

ក៖ ចាសលោកយាយ! កាលនឹងពិបាកមែនលោកយាយ!

ខ៖ ពិបាកណាស់ចៅ!

ក៖ លោកយាយឈឺច្រើនដែរទេលោកយាយ?

ខ៖ ឈឺ....ឈឺបើអ្នកណាគេកំលាំងខ្លាំងអញ្ចឹងគេចេះលួច (សើច) មិនមែនថាគេចេះលួចដូចថាគេធ្វើជាឈឺអញ្ចឹងឯងទៅហើយទៅចឹងឯងទៅលួចបាយក្តាំងបាយអីអញ្ចឹងឯង
ហើយទៅលួចលាក់មួយក្តាប់មួយអីអញ្ចឹងឯងណាស់(មានសំលេងរំខានពីខាងក្រៅ)
អានឹងបានហូបបានរ៉ុងពោះអញ្ចឹងឯងណាស់នឹងវារបៀបថាដូចសុំលួចសុំចុងភៅអីអញ្ចឹងទៅណាស់ចៅ!

ក៖ ចាសលោកយាយ!

ខ៖ តែខ្ញុំនឹងទៅចំត្រង់កន្លែងដែលពិបាក កន្លែងរបស់ខ្ញុំនឹង!

ក៖ ចុះគេមានដែលធ្លាប់ធ្វើបាបលោកយាយដែរឬទេលោកយាយ?

ខ៖ ខ្ញុំអត់អីទេមិនសូវអីទេ!

ក៖ អញ្ចឹងពិបាករបៀបណាខ្លះទៅលោកយាយ?

ខ៖ ពិបាកនឹងដូចថាយើងឈឺច្រើនគេប្រើធ្វើការអីនឹងយប់ឡើងនឹងធ្វើទៅ ហើយទៅយើងចេះតែធ្វើអោយគេទៅ

វាដូចថាយើងងើបធ្វើម៉ោងបីម៉ោងអីអញ្ចឹងនឹងធ្វើរហូតទៅដល់ម៉ោង១០យប់អីបានគេអោយយើងឈប់សំរាក ហើយដេកនឹងម៉ោងបួនម៉ោងបីអីនឹងគេហៅយើងទៅទៀតហើយវាអញ្ចឹងណាស់ វាពិបាកអញ្ចឹងពិបាកតែរឿងនឹងអញ្ចឹងម៉ងណាស់ចៅ ហើយយើងចេះធ្វើទៅតាមគេប្រាប់នឹងឯងទៅណាស់ចៅយើងណាទៅហ៊ានតវ៉ានឹងគេនោះ!

ក៖ ចាសត្រូវហើយលោកយាយ! ចុះលោកយាយកាលពេលដែលជំនាន់ប៉ុលពតនឹងលោកយាយមានចងចាំអីគេខ្លះកាលជំនាន់នឹង?

ខ៖ អើ! ចងចាំនឹងដូចថាយើងធ្វើការលើកទំនប់ ស្ទូង លើកភ្លឺ ដាំជំលូវ យើងជាកងចល័តឃុំអញ្ចឹងនឹងចង់គេប្រើធ្វើអីក៏តែបាននឹង ជូនណាទៅគេប្រើអោយទៅដាំជំលូវនឹងទៅ ហើយជូនណាទៅគេប្រើអោយយើងនឹងទៅលើកភ្លឺអញ្ចឹងទៅ ពេលខ្លះទៅអោយទៅរែកដីឡើងទំនប់ចាក់ទំនប់អញ្ចឹងទៅស្រេចតែគេប្រើទេ! (មានសំលេងរំខានពីខាងក្រៅ)!

ក៖ អឹម.....

ខ៖ នឹងវាពិបាកណាស់នឹងវាស្រេចតែគេប្រើយើងទៅទេ ដូចថាយើងវានៅកំពុងពេញកំលាំងអញ្ចឹងនឹងឯងគេចេះតែប្រើយើងទៅចឹងណាស់ចៅ!

ក៖ ចាសលោកយាយ!

ខ៖ ប៉ុន្តែគ្រាន់តែថាខ្ញុំនឹងជាកងចល័តឃុំខ្ញុំមិនមែនកងចល័តស្រុកចល័តតំបន់ទេ ដូចថាយើងនៅវិលតែនឹងភូមិអញ្ចឹងណាស់ដូចថាធ្វើពីភូមិនេះហើយអញ្ចឹងទៅក៏ទៅភូមិមួយទៀតអញ្ចឹងទៅ!

ក៖ ចាសលោកយាយ!

ខ៖ នឹងគេហៅថាកងចល័តឃុំ ដល់ពេលតែកងចល័តឃុំយើងដើរតាមភូមិ បើកងតំបន់វិញគេដើរតាមស្រុក នឹងអញ្ចឹងណាស់ចៅបើដូចស្រុកអញ្ចឹងគេហៅតំបន់ ហើយបើដល់ពេលដែលយើងឈឺអញ្ចឹងនឹងគេអោយយើងទៅតាមឃុំ

ដូចថាមួយឃុំនឹងអញ្ចឹងនឹងយើងដើរដូចគេថាហ៎ ទៅលើកភ្លឺភូមិនេះហ៎គេថាត្រូវការកំលាំងអោយទៅជួយដាំដំលូវនៅនឹងភូមិនោះ!

កៈ ចាសលោកយាយ!

ខៈ នឹងយើងៗនឹងគេហៅថាភូមិហើយ! តែនៅជំនាន់នោះគេហៅឃុំវិញវាអញ្ចឹងណាស់!

កៈ ចាសលោកយាយ!

ខៈ ហើយដូចថានៅក្នុងមួយឃុំនឹងមានប៉ុន្មានឃុំអញ្ចឹងណាស់!

កៈ ចាសលោកយាយ!

ខៈ នឹងកាលនឹងគេបែងចែកអញ្ចឹងណាស់ គេប្រើយើងអញ្ចឹងយើងពិបាកនឹងគេប្រើយើងអោយទៅធ្វើការរបៀបអញ្ចឹងនឹងហើយទៅយើងពិបាកត្រង់ថាយើងគេអោយយើងហូបវាអត់គ្រាប់គ្រាន់អញ្ចឹងណាស់!

កៈ អឹម.....

ខៈ នឹងហើយគេមិនអោយយើង! ដូចថាកាលនឹងខាងសន្សំសំចៃ(សើច)!

កៈ (សើច)!

ខៈ គេលើកមកនិយាយអញ្ចឹងគេថាគេសន្សំសំចៃតិចទ្រាំគេថាគេអោយយើងនឹងទ្រាំទៅតែបន្តិចទៅគេអោយយើងបានហូបបានមួយថ្ងៃបីដងហើយ!

កៈ អឹម.....

ខៈ ហើយដូចថាខាងនៅខាងខ្ញុំអញ្ចឹងនឹងគេអោយអត់យើងហូបគ្រាប់ទេបើថាយើងហូបអត់កើតអញ្ចឹងនឹងយើងថាសម្លរនឹងហូបអត់កើតអញ្ចឹងយើងសុំអំបិលគេអញ្ចឹងនឹងគេថាយើងនឹងទស្សនណាស់ស៊ីរកតែឆ្ងាញ់ អំបិលណាស់អូនណាស់មានអីចុះបើយើងហូបសាបលេបវាមិនកើតនោះ ខាងខ្ញុំអំបិលយកទៅដាក់នៅលើចុងឈើណាស់ដល់តែកងចល័តមកយកអញ្ចឹងនឹងអាមកអាដើមឈើរលំនឹងមកយើងទៅយើងទៅកើបអំបិលនឹងយកមកហូបទៅ នឹងខាងខ្ញុំណាស់ខាងគេដទៃខ្ញុំអត់ដឹងទេណាស់!

កៈ ចាសលោកយាយ!

ខ៖ ប៉ុន្តែនៅខាងខ្ញុំនឹងខ្ញុំនៅចំកន្លែងដែលពិបាក!

ក៖ ចាសលោកយាយ!

ខ៖ ក៏ប៉ុន្តែនៅពេលដែលជិតបែកនេះយើងនិយាយកុំអោយបាប!

ក៖ អឹម......

ខ៖ ដូចថាគេធ្វើបង្អែមអោយយើងមួយអាទិត្យនឹងម្តង អញ្ចឹងណាស់!

ក៖ ចាសលោកយាយ!

ខ៖ នឹងនៅពេលដែលជិតបែកយើងជិតបែកមែនទែនហើយណាស់(មានសំលេងរំខានពីខាងក្រៅ)!

ក៖ អឹម.....

ខ៖ នឹងគេធ្វើអោយហូបដែរ! ដូចថាគេដឹងរឿងពីណាមកអញ្ចឹងនឹងគេធ្វើលើកទឹកចិត្តរបស់យើងអញ្ចឹងទៅណាស់!

ក៖ អឹម!

ខ៖ ចាស!

ក៖ បានតែម្តងនឹងទេហ៎លោកយាយ?

ខ៖ កាលនឹងបានបីប្អូនដងរបស់គេដែរយើងនិយាយការពិតទៅកុំអោយបាបធ្វើអោយយើងហូបដូចថានៅក្នុងមួយអាទិត្យនឹងម្តងមួយខែនឹងម្តងអីអញ្ចឹងអោយយើងហូបទៅណាស់អូនណាស់!

ក៖ ចាសលោកយាយ! ហើយទៅនៅពេលដែលដាច់នឹងលោកយាយអឺ....កាលនឹងនៅជុំជាមួយគ្រួសារវិញឬក៏លោកយាយបែក....

ខ៖ អត់ទេបែកគ្នាតាំងពីពេលនឹងមក រស់នៅតែម្នាក់ឯងនឹងទៅហើយបានទៅនៅជាមួយនឹងបងរបស់ឪពុកចិញ្ចឹមខ្ញុំនឹង!

ក៖ បែកគ្នាហ៍លោកយាយ?

ខ៖ បែកកាលនៅ៧៩នឹង(ឆ្នាំ១៩៧៩)!

ក៖ អូ....គាត់បែកនឹងរបៀបម៉េចវិញលោកយាយ?

ខ៖ បែកនឹងយើងធ្វើស្រែរួម (មានសំលេងរំខានពីខាងក្រៅ)! ធ្វើស្រែរួមអញ្ចឹងឯងទៅពេលបានផលចែកគីឡូគ្នាទៅ!

ក៖ បែកស្រួលហើយអញ្ចឹងកាលនឹង អត់មានបាញ់គ្នាអីទេហ៍លោកយាយ?

ខ៖ បាញ់ខាងខ្ញុំនឹងគេបាញ់គ្នាតើចៅ! ដូចថាខាងគេមកអញ្ចឹងនឹងគេចូកមកដល់នឹងគេបាញ់ដូចថាគេបាញ់កម្មាយសត្រូវអីអញ្ចឹងណាស់គេមិនបាញ់យើងទេ
ដូចថាគេបាញ់អ្នកណាដេញអ្នកណាចឹងនឹងក៏មិនដឹងដែរព្រោះយើងជាប្រជាជនណាស់ដល់អញ្ចឹងយើងអត់ដឹងទេ ហើយទៅគេដេញយើងមកអញ្ចឹងនឹងយើងចេះតែមកម៉ោ ដូចថាទៅអញ្ចឹងនឹងមិនដឹងទៅឯណាមកឯណីទេចៅ យើងអត់ដឹងរឿង
បើនិយាយទៅយើងសម័យនឹងមនុស្សវាល្ងង់ផងទាំងគេទាំងយើង
គ្មានទៅចេះដឹងខាងនយោបាយនយោបោកស្អីគេនឹងមិនទាំងដឹងផង
នៅល្ងង់ណាស់បើនិយាយទៅនោះយើងវាល្ងង់ម៉ងណាស់ចៅ
គេប្រើអោយលិចទៅលិចគេប្រើអោយទៅកើតទៅកើត
អញ្ចឹងនៅពេលដែលចេញមកនឹងអាយួនចូលមកនឹងម៉េចក៏យើងមិនដឹងដែរអាម៉េចៗនឹងក៏យើងវាមិនដឹង ដឹងភ័យតែគ្រាប់ផ្លោងនឹងបិះៗនឹងត្រចៀក!

ក៖ អឺម!

ខ៖ នៅពេលដែលគេឡើងទៅនឹងគេមិនរំដោះ ដល់តែគេរំដោះនឹងគេចេះតែបាញ់ទៅមិនដឹងថាអ្នកណាអ្នកណី
បាញ់ដើម្បី....មិនដឹងថាគេបាញ់អ្នកណាមិនដឹងថាគេបាញ់ខ្មែរក្រហមមិនដឹងថាគេបាញ់យើង
បើយើងចេះតែក្រាបផងរត់ផងនឹង
ហើយទៅភ័យនាងមិនដឹងថាគ្រាប់នឹងវាត្រូវគេឬក៏ត្រូវយើងនាងអើយ!

ក៖ ត្រូវហើយលោកយាយកាលនឹងនោះ!

ខ៖ យើងនៅក្មេងយើងមិនភ័យ! ហើយណាមួយនឹងវាអត់មានអីហូបទៀតផងអីផងនឹងយើងទៅមានកំលាំងមកពីណាទៅរត់ទៅដឹង.....

ក៖ ហើយទៅបងប្អូនអីអត់ដឹងថាទៅណាលោកយាយអត់មានបងប្អូនទៀតកាលនឹង? នៅតែម្នាក់ឯង?

ខ៖ នៅតែម្នាក់ឯង ពីរនាក់យាយនឹងយកខ្ញុំទៅចិញ្ចឹមនឹងហើយយាយនឹងគាត់ចាស់ហើយគាត់អាយុ៨០ឆ្នាំជាងហើយៗទៅគាត់.....

ក៖ លោកយាយនឹងគាត់មានឈ្មោះអីដែរលោកយាយ?

ខ៖ គាត់ឈ្មោះ ទេព អោក!

ក៖ គាត់មានកូនចៅដែរឬទេលោកយាយ?

ខ៖ អត់មានទេកូនរបស់គាត់ស្លាប់ទាំងអស់នឹង!

ក៖ អត់មានកូនដែរ!

ខ៖ កូនៗរបស់គាត់នឹងស្លាប់ទាំងអស់នឹង!

ក៖ ចាសលោកយាយ!

ខ៖ គាត់ពេលដែលជំលៀសនឹងគាត់ទៅតាមខ្ញុំហើយនឹងឪពុករបស់ខ្ញុំនឹងតើគាត់គ្មានអីទេមានតែកន្ទ្រក់ស្លាមួយទេ!

ក៖ អឹម! ចុះលោកយាយកាលនឹងនៅពេលដែលបែកមកលោកយាយរៀបការអឺ....ដូចជា.....

ខ៖ ខ្ញុំរៀបការនៅក្នុងឆ្នាំ៨៥(១៩៨៥) ហើយ!

ក៖ ចាសៗលោកយាយ! លោកយាយរៀបការដោយសារតែស្រលាញ់គ្នាដែរន៏លោកយាយកាលនឹងលោកយាយ?

ខ៖ ចាសចៅ!

ក៖ ហើយ.....

ខ៖ ស្រលាញ់ចិត្តនឹងចិត្ត!

ក៖ ចាសលោកយាយស្រលាញ់គ្នាដោយចិត្តនឹងចិត្ត!

ខ៖ ចាស!

ក៖ ហើយចុះលោកយាយនឹកឃើញយ៉ាងម៉េចបានជាលោកយាយស្រលាញ់លោកតា?

ខ៖ ក៥!

ក៖ ចាស?

ខ៖ ក៥!

ក៖ ក៥ យ៉ាងម៉េចវិញទៅលោកយាយ?

ខ៖ មួយរឹក(មួយរយះពេល) ដែកគេអោយកាប់ព្រៃ ក៥ នឹងព្រោះអីកាលនឹងខ្ញុំនៅតែម្នាក់ឯងខ្ញុំមកពីអាពតវិញអញ្ចឹងនឹងខ្ញុំមកតែម្នាក់ឯងធ្វើផ្ទះមួយនៅតែម្នាក់ឯងអញ្ចឹងណាស់!

ក៖ ចាសលោកយាយ!

ខ៖ ដល់តែហើយទៅយើងក្រមុំ!

ក៖ អឹម!

ខ៖ ដល់តែយើងក្រមុំវាចាស់ៗបន្តិច...អើធម្មតាយើងនៅក្រមុំនៅផ្ទះតែឯងអត់មានម៉ែអត់ឪអត់បងអត់ប្អូននោះ!

ក៖ ចាសលោកយាយ!

ខ៖ ដល់ហើយទៅបន្តិចប្តីអ្នកលើកដាក់អ្នកនោះអ្នកនោះលើកដាក់អ្នកនេះអាប្រពន្ធរបស់គេនោះប្រច័ណ្ឌទៅរករឿងយើងចេះតែចោទយើងថាស្រលាញ់អ្នកនេះស្រលាញ់អ្នកនោះ!

ក៖ អូ.....

ខ៖
ស្រលាញ់ប្ដីគេអញ្ចឹងទៅហើយអ្នកខ្លះគេមកជេរបញ្ចោរយើងហើយទៅយើងអត់ទេយើងអត់មានបានទៅធ្វើរឿងអញ្ចឹងសោះ!

ក៖ អឹម!

ខ៖ ទៅដល់ហើយក៥ នឹងចាស់ៗគាត់នៅនឹងគាត់ថាឯណោះប្ដីរបស់ខ្ញុំនឹងគាត់ចេះតែទៅលេងគាត់ឃើញខ្ញុំអញ្ចឹងនឹងគាត់ស្រលាញ់ខ្ញុំអញ្ចឹងណាស់!

ក៖ អឹម!

ខ៖ គាត់ថា...ចាស់ៗគាត់ថាហ៎ហាងអើយបើឯងនៅទៅឯងក៏វាចាស់ដែរ អាយុ២៦ឆ្នាំ ២៧ឆ្នាំហើយ
នែ....ឯងសាកគិតមើលទៅបើឯងមិនយកមកវាហើយវាកំលោះហើយថ្វីត្បិតតែវាខ្វាក់ក៏មិនមែនឯង បើសិនជាឯងយកអ្នកល្អអោយតែក៥ ទៅកាប់ព្រៃមកវិញដាច់ដៃដាច់ជើងដូចតែគ្នាហើយបើឯងទ្រាំនៅអញ្ចឹងបន្តិចប្ដីអ្នកចោទ
ប្ដីអ្នកនោះហើយអាមនុស្សប្រុសនឹងក៏វាចេះតែមើលងាយអញ្ចេកអញ្ចុះ
អញ្ចឹងហើយឯងយកវាទៅទោះវាខ្វាក់វាខ្វិនអី
ដូចថាវាឯងយកវាទៅទោះបីជាខ្វាក់ម៉េចម៉ាក៏មិនមែនខ្វាក់តែថ្ងៃនឹងទេហើយណាមួយគេនៅកំលោះផង ហើយយកទៅឯងទៅរកស៊ីឯណាក៏ទៅៗចាស់ៗគាត់ចាប់ផ្សំអោយអញ្ចឹងទៅហើយយើងយកមកដេកគិតណាស់!

ក៖ អឹម!

ខ៖ ផ្អៀងខ្លួនមកអញ្ចឹងឯងទៅយកមកដេកគិតមនុស្សអញ្ចឹងក្រែងលរខ្វាក់ខ្វិនអីទៅ! ហើយដល់ពេលតែគាត់ចេះតែបញ្ចុកបញ្ចូរអីទៅដូចថាយើងត្រចៀកស្រាលដែរនឹងណាស់!

ក៖ (សើច)!

ខ៖ ស្ដាប់តាមចាស់នឹងទៅថាជាគូរបស់យើងនឹងក៏ថាបាន អឹមយកវាទៅវាមិនមែងឯងការថ្ងៃនឹងហើយទៅស្អែក
ម៉េចក៏វាត្រឹមជាបង្គោលនៅក្នុងគ្រួសារដែរគិតមើលទៅវានៅកំលោះណាស់!

ក៖ អឹម!

ខ៖ សោះនឹងគេថាអោយង៉ែងយកប្តីអ្នកនេះ ប្តីអ្នកនោះទៅវាសមនឹងអាប្រុសអស់នឹងវាថា តែនេះគេនៅកំលោះ!

ក៖ ចាសៗលោកយាយ!

ខ៖ អឺម! គាត់បញ្ចុះបញ្ចូលអញ្ចឹងណាស់ ហើយយើងចេះតែគិតទៅណាស់នាង!

ក៖ អញ្ចឹងហើយបានលោកយាយបានរៀបការមានអាពាពិពាហ៍អីត្រឹមត្រូវ?

ខ៖ ចាសរៀបការមានលោកមានអីត្រឹមត្រូវ យើងការនៅសម័យនោះមានអីកូនអើយមានតែមន្តលោកសូត្រមន្តអីនឹងឯង!

ក៖ ហើយលោកយាយមានកូនប៉ុន្មាននាក់?

ខ៖ ខ្ញុំមានកូនពីរនាក់(មានសំលេងរំខានពីខាងក្រៅ)!

ក៖ ពីរនាក់អឺ....ដូចលោកយាយប្រាប់មុននឹងហ៎ថា......

ខ៖ ចាសចៅ!

ក៖ ហើយសព្វថ្ងៃនឹងទាំងពីរនឹងហ៎លោកយាយ?

ខ៖ មួយនឹងលង់ទឹកស្លាប់បាត់ហើយនាង!

ក៖ គាត់....អឺ....ស្លាប់នៅក្នុងឆ្នាំណាដែរលោកយាយឆ្នាំគាត់ស្លាប់ណាស់?

ខ៖ ឆ្នាំ១៩០០...ឆ្នាំប៉ុន្មានឪវាអាពេជ្រស្លាប់?

គ៖ ១៤....២០១៤ (សំលេងរបស់ប្តីលោកយាយ)!

ខ៖ ២០១៤!

ក៖ អូ....

ខ៖ ទើបនឹងស្លាប់ដែរ រៀនខាង អាយធី ឆ្នាំទីបីរៀនជិតចប់ហើយនឹង!

ក៖ អូ....សោកស្តាយណាស់លោកយាយ!

ខ៖ កុំអីនឹងបានកូន ខ្ញុំឡើងអស់ពីខ្លួនណាស់ ខ្ញុំចង់ឆ្កួតបន្តិចអីបន្តិចណាស់រាល់ថ្ងៃនឹងខ្ញុំចង់ឆ្កួតចបន្តិចជាបន្តិចណាស់កូន អត់ពន្យា ដូចថាគេថាអត់ពន្យាអត់ស្អីរំពឹងអញ្ចឹងណាស់!

ក៖ អឺម! ចុះកូនរបស់លោកយាយមួយទៀតហ៎?

ខ៖ មួយទៀតនឹងគេមានប្រពន្ធមានកូនហើយប៉ន្តែដូចថាមានប្រពន្ធនឹងឯងទៅវាទៅនៅខាងប្រពន្ធរបស់គេបាត់ទៅគេមិនមករកយើងទេ!

ក៖ អញ្ចឹងគាត់មិនសូវបានមករកលោកយាយទេ?

ខ៖ អត់បានមកតែម៉ង!

ក៖ ម៉េចអញ្ចឹងលោកយាយ?

ខ៖ ដឹងម៉េចដែគេ!

ក៖ ម៉េចក៏គេមិនសូវជាបានមកលេងនឹងលោកយាយ?

ខ៖ គេខិតខំប្រឹងប្រែងរកស៊ីប្តីប្រពន្ធគេកូនអើយ!

ក៖ អឺម!

ខ៖ ប៉ុន្តែយើងក៏មិនចង់ទៅពឹងលើគេនឹងដែរ!

ក៖ គាត់រកស៊ីមុខរបរអីដែរលោកយាយ?

ខ៖ វាធ្វើសន្តិសុខ!

ក៖ អ៎.....

ខ៖ នោះរូបថតអាដែលស្លាប់ទៅនោះ នៅក្នុងវត្តនឹង(មានសំលេងរំខានពីខាងក្រៅ) ឆ្អឹងក៏នៅក្នុងកុដិនឹងដែរហើយទៅរូបថតក៏នៅនឹងដែរ!

ក៖ មូលហេតុអីបានជា.....កាលនឹងលោកយាយគាត់លង់ទឹករបៀបណាដែរបានជាគាត់ដូចជាធំដែរហើយមិនសមណានឹងស្លាប់?

ខ៖ ២៣ឆ្នាំណាស់កូន!

ក៖ នឹងហើយមិនសមថាគាត់លង់ទឹកស្លាប់អញ្ចឹងណាស់ ត្រូវប្រយ័ត្ន!

ខ៖ សុំទៅលេងប្រាំពីរវត្ត ភ្នំណាស់ខែទឹកឡើង!

ក៖ អឺម....

ខ៖ ណ៍....ឯស្ទឹគែ....ស្អាងៗយើងនៅនឹងខេត្តកណ្តាលនេះ!

ក៖ អឺម!

ខ៖ កោះខ្សាច់ទន្លេនេះ!

ក៖ អូ.....

ខ៖ កាលនឹងលង់ប្រាំមួយនាក់!

ក៖ អូ....

ខ៖ ស្រង់បានបួនអ្នក ស្លាប់នឹងពីរនាក់ កូនរបស់យើងមួយកូនរបស់គេអ្នកមាននឹងមួយ គេនៅ....គេខាងនៃ....អេស៊ីលីដា ហើយកូនរបស់យើងរៀនចប់ឆ្នាំនឹងខាងអាយធី!

ក៖ អូ.....

ខ៖ អញ្ចឹងណាស់ លង់នឹងជិះទូកទាំងប្រាំមួយនាក់នឹងដំណើរនឹងបាយរួចហើយនាំគ្នាជិះទូកលេងណាស់!

ក៖ អឺម!

ខ៖ នាំគ្នាជិះទូកលេងនៅតាមច្រាំងនឹងស្រាប់តែគេនឹងបើតាមគេនិយាយខ្ញុំអត់ឃើញទេណាស់ព្រោះអីវាស្លាប់នៅម៉ោងពីរហើយ ម៉ោងប្រាំមួយបានគេអោយយើងដឹង!

ក៖ អឺម!

ខ៖ ដឹងខ្ញុំចង់ឆ្កួតបណ្តោយ!

ក៖ ចាសលោកយាយ!

ខ៖ ដូចថាវាយើងភ្លាមពេកណាស់!

ក៖ គេថាម៉េចដែរលោកយាយកាលនឹង?

ខ៖ គេថាវាអ៊ុំទូកលេងទេ បាយហើយនឹងណាស់ហើយទៅឪវាគេសួរថាពេជ្យហែងដល់ណាហើយម៉ែហែងនឹងចាំហូបបាយ ដល់ហើយអឹមថាវាជិតដល់ហើយនៅស្អាងជិះទូកហើយអាទូកចាមនឹងវាៗមកនឹងវាម៉ាស៊ីនហើយទៅទូកយើងនឹងអ៊ុំដៃ ហើយនៅពេលដែលយើងមកដល់ឆាវអញ្ចឹងទៅដូចយើងនៅលើគោកអីអញ្ចឹងណាស់ហើយនោះទឹកវាមិនសាចទឹកនឹងជះចូលហើយទៅទូកនឹងតូចនឹងហើយគ្នាដល់ទៅប្រាំមួយនាក់ឯណោះអញ្ចឹងវាសាចនឹងទឹកនឹងឯងទៅ....

ក៖ លិចទឹកទៅ!

ខ៖ ផ្អៀងទូកផ្អៀងអីចុះឡើងនឹងមួយភ័យអាមួយស្រែកមិនស្រវាខុសៗ ហើយមនុស្សសុទ្ធតែអស់ធំហើយ២៦ឆ្នាំ ២៧ឆ្នាំហើយ!

ក៖ ហើយទៅគាត់ចេះហែលទឹកដែរឬទេលោកយាយ?

ខ៖ អឹម! ចេះហែលអីវាសុទ្ធតែអត់ចេះហែលទឹកទាំងអស់គ្នា!

ក៖ អត់ចេះហែលទឹកទាំងអស់គ្នា(សើច)!

ខ៖ ចឹងបានថានឹងអត់ចេះហែលទឹកហើយនាំគ្នាទៅលេង នឹងឯងណាស់កូនខ្ញុំថាបើសិនជារួចខ្ញុំវៃអោយងាប់ណាស់វៃអោយងាប់នឹងដៃខ្លួនឯងនឹងម៉ង ខឹងពេកណាស់!

ក៖ (សើច) គាត់ៗខ្វះដូចថាការប្រុងប្រយ័ត្នណាស់លោកយាយ!

ខ៖ វាដឹងតែសប្បាយក្មេងវាដឹងតែសប្បាយ!

ក៖ សោកស្តាយមែនទែនលោកយាយ!

ខ៖ សប្បាយក្មេងៗសម័យឥលូវនឹងវាច្រើនតែអាមិត្តភក្តិគួរកននឹងអើយយើងនិយាយវាមិនស្តាប់យើងប្រាប់វាមិនចូលដើរទៅចឹងខ្ញុំប្រាប់ណាស់ដើរទៅណាក៏ដោយទៅភ្នំក៏ដោយកូនឯងមានធូបមានទៀនអីនឹងអុចសុំគេយើងទៅមើលគេមិនឃើញទេកូន!

ក៖ អឹម!

ខ៖ តែនៅលើក្បាលយើងនឹងក៏មានអ្នកថែរក្សាដែរ បើយើងមិនដឹងទេយើងកុំប្រមាថប៉ុន្តែមិនដឹងជាគេថាមកពីខុសមាត់ទៅក៏មិនដឹងស្អីទៅក៏មិនដឹងដែរណាស់កូន យើងលឺតែគេថា ហើយយើងឯណោះវាចង់ឆ្កួតតិចចង់ជាបន្តិចរាល់ថ្ងៃនឹងវាអត់ដឹងថាខ្លួនឯងនឹងគ្រប់ប៉ុន្មានដែរ!

ក៖ (សើច)!

ខ៖ ដល់ពេលនេះទៅយើងវាចេះតែនឹកឃើញវានឹងឯងដូចថាយើងមើលទៅចិត្តថ្លើមរបស់វានឹងអាចថាគិតឪពុកម្តាយបើទោះតែវាមានប្រពន្ធទៅក៏វាដូចថានៅក្នុងចំណោមមួយរយក៏វាបានមួយកូនចំរៀកតូចដែរ!

ក៖ ចាសលោកយាយ!

ខ៖ បើដូចអាបងវានឹងយើងអត់សង្ឃឹមទេ យើងដឹងតាំងពីដើមដៃនឹងអញ្ចឹងមក!

ក៖ អ៊ឹម!

ខ៖ បើប្អូននឹងយើងអាចពឹងពាក់បានណាស់!

ក៖ ហើយទៅគាត់រៀបនឹងលោកយាយជាអ្នករៀបអោយគាត់ឬក៏គាត់រកលុយរៀបការខ្លួនឯង?

ខ៖ ពីណាគេអាបងហ៎?

ក៖ ចាសលោកយាយ!

ខ៖ អាបងរកលុយរៀបការខ្លួនឯងនឹង វារកលុយខ្លួនឯង!

ក៖ អ៊ឹម!

ខ៖ អ៊ឹម! មិននឹកស្មានថាវាទៅជាអញ្ចឹងទេកូនអើយ អានឹងជាកម្មរបស់យើងទេមានតែទទួលទៅ!

ក៖ ដូចថាជីវិតរបស់មនុស្សយើងកើតមកដូចថាកម្មនៅក្នុងជីវិត......

ខ៖ ត្រូវហើយនឹងជាកម្មរបស់យើង!

ក៖ របស់មនុស្សម្នាក់ៗនឹងគឺផ្សេងៗគ្នា!

ខ៖ ចាស យើងក៏មិនចង់ជួបនឹងរឿងអញ្ចឹងដែរ!

ក៖ ចាសលោកយាយ!

ខ៖ កម្មរបស់យើងមកពីនៅជាតិមុននឹងយើងមិនបានកសាងជាមួយនឹងវាច្រើនបានតែវាក៏មិនត្រូវនៅបំរើយើង ហើយយើងក៏មិនត្រូវបានស៊ីកំលាំងវាយើងគិតអញ្ចឹងណាស់កូន!

ក៖ អ៊ឹម! អញ្ចឹងនៅពេលដែលលោកយាយពិបាកចិត្តម្តងៗនឹងលោកយាយធ្វើអីគេខ្លះលោកយាយ?

ខ៖ ចាស??

ក៖ នៅពេលដែលលោកយាយពិបាកចិត្តម្តងៗលោកយាយធ្វើអីគេខ្លះ?

ខ៖ យាយអត់សូវអីដែរនឹង គ្រាន់តែថាពេលដែលនឹកចឹងនឹងទៅមួយឆាវអញ្ចឹងទៅហើយធ្វើនេះធ្វើនោះបន្តំទៅលែងអីហើយកូន!

ក៖ ចាសលោកយាយ!

ខ៖ ព្រោះជីវិតរបស់យើងៗដឹងថាតាំងពីដើមរហូតទៅដល់បញ្ចប់គឺអញ្ចឹងរហូតនឹង!

ក៖ អ៊ឹម!

ខ៖ មានដូចថា....ឥលូវថាខ្លួនឯងកំព្រាចុះអត់ម៉ែអត់ឪអញ្ចឹងណាស់!

ក៖ ចាសលោកយាយ!

ខ៖ ហើយដល់តែពេលមានប្តីៗក៏ពិការណាស់!

ក៖ អ៊ឹម!

ខ៖ ហើយដល់តែពេលមានកូនៗចិត្តមិនបានដល់តែពេលដកពីអាមិនបានមកដាក់នឹងអាបានស្លាប់បណ្តោយ អញ្ចឹងនៅក្នុងជីវិតរបស់យើងគឺគ្មានទីពឹងអីទេ!

ក៖ អ៊ឹម!

ខ៖ នេះតស៊ូប្រឹងអោយវារៀនណាស់ខ្ញុំធ្វើសៈធម៌នឹងមកតាំងពីសៈធម៌មួយរណ្តាប់បីពាន់ណាស់!

កៈ អឺម!

ខៈ ចិញ្ចឹមកូនបានឡើងរហូតដល់កូនរបស់បានឡើងបាក់ឌុបបានឡើងមហាវិទ្យាល័យទាំងអស់(មានសំលេងរំខានពីខាងក្រៅ) ចុងបញ្ចប់ខ្ញុំបាតដៃទទេ(មានសំលេងរំខានពីខាងក្រៅ)!

កៈ អឺម!

ខៈ ចុងបញ្ចប់ប៉ុណ្ណឹង!

កៈ លោកយាយកុំបាក់ទឹកចិត្តអីណាស់លោកយាយណាស់ ដោយសារតែជីវិតរបស់យើងទៅអញ្ចឹងហើយមនុស្សម្នាក់ៗក៏មានការលំបាកនឹងផ្សេងៗពីគ្នា ហើយយើងក៏មើលវាមិនឃើញដែរណាស់លោកយាយ សូមសរសើរលោកយាយដែលលោកយាយខិតខំតស៊ូមក....

ខៈ តស៊ូមករហូត!

កៈ ចាសតស៊ូខិតខំមករហូត!

ខៈ ចង់ដឹងថាវាយ៉ាងម៉េចទៅនៅទីបញ្ចប់របស់ជីវិតមនុស្ស តែជីវិតរបស់ខ្ញុំនេះចុងបញ្ចប់បាតទទេរ ពិបាកមកប៉ះចំកូនដែលចិត្តមិនបានហើយអាកូនប្អូននឹងក៏ស្លាប់ទៅទៀតនឹង ខ្ញុំដូចនាងបដាច្ឆា!

កៈ អឺម!

ខៈ ចំកូនដែលមានចិត្តមិនបាននឹង អញ្ចឹងបានថាមានតែពីរនាក់យាយតានឹងឯងទៅ(មានសំលេងរំខានពីខាងក្រៅ)!

កៈ អឺម! លោកយាយអើយ!

ខៈ (សើច)!

កៈ អឺ....ឥលូវនឹងលោកយាយនៅមានលោកតាដែរន៍លោកយាយ?

ខៈ ចាស!

កៈ អញ្ចឹងនឹងយើងចេះតែចាប់ដៃគ្នាថែរក្សាគ្នាទៅលោកយាយ!

ខ៖ ចាសមានតែយើងពីរនាក់យាយតាថែរក្សាគ្នានឹងឯងទៅមានក្រលំបាកម៉េចក៏ដោយណាស់កូន!

ក៖ ចាសលោកយាយ! (មានសំលេងរំខានពីខាងក្រៅ) ហើយអឺ....លោកយាយជីវិតរបស់លោកយាយតាំងពីមុននឹងរហូតមកដល់ឥលូវនឹងលោកយាយមានចងចាំអីគេដែលធ្វើអោយលោកយាយនឹកឃើញហើយពិបាកចិត្តបំផុតណាស់?

ខ៖ អ៊ឹម.....សឹងៗតែពិបាកចិត្តទាំងអស់នឹងហើយ វាសឹងៗតែថារឿងដែលពិបាកចិត្តទាំងអស់នឹង!

ក៖ អ៊ឹម!

ខ៖ តាំងពីកូនធ្វើបាបសព្វគ្រប់វាជក់វាអី ទម្រាំនឹងវាបានប៉ុណ្ណឹង ខ្ញុំថាជីវិតរបស់ខ្ញុំនឹងវាជួបច្រើនណាស់អារឿងពិបាកនឹងវា
អញ្ចឹងបានថាជីវិតអ្នកណាដែលមានកូនមិនធ្វើបាបណាស់
មិនអោយស៊ីក៏អត់ខឹងដែរកុំអោយតែវានឹងធ្វើបាបផ្លូវចិត្តរបស់យើងកុំអោយតែធ្វើបាបផ្លូវចិត្ត!

ក៖ អ៊ឹម!

ខ៖ បើស្រណុកអីអាចទ្រាំបានបន្តិច!

ក៖ ចាសលោកយាយ!

ខ៖ ទ្រាំបានបន្តិច ប៉ុន្តែគ្រាន់តែថាកូនរបស់ខ្ញុំអាបងនឹងវាដូចតែថាវាបំផ្លាញតាមរបៀបអ្នកក្រអញ្ចឹងណាស់(សើច) វាអត់មានទៅជាប់គុកជាប់ចង្វាក់អីទេគ្រាន់តែថាវាពិបាកមិនស្តាប់យើងអីអញ្ចឹងទេ ថាខ្ញុំជួបរឿងដេលពិបាកសំសត់នឹងក៏ថាបាន
សឹងតែថាពិបាកនឹងវាទាំងអស់ទៅហើយរកអាចំនុចណាដែលថាវាអត់លំបាកនឹងអត់មាន វាមានតែទាំងអស់នឹង(មានសុទ្ធសឹងតែជារឿងលំបាក)!

ក៖ អ៊ឹម! ចុះលោកយាយចំពោះរឿងល្អៗដែលមាននៅក្នុងជីវិតរបស់លោកយាយវិញមានដែរឬទេ?

ខ៖ អត់សូវមានទេកូន!

ក៖ អឺម!

ខ៖
ទើបតែឥលូវនឹងយើងរៀងគ្រាន់បើបន្តិចព្រោះអីយើងវាអស់ពីកូនពីចៅដែលត្រូវគិតគូរទៅយើងវាដេកក៏វាស្រួលលែងគិតពីកូនណាទាំងអស់ ពេលដែលយើងគិតតែពីប្រវត្តិខ្លួនយើងអញ្ចឹងទៅណាស់!

ក៖ ចាសលោកយាយ! មកពឹងលើព្រះធម៌នឹងឯងទៅ!

ខ៖ នឹងហើយ តាមយៈថាកម្មរបស់យើងអញ្ចឹងឯងទៅធ្វើម៉េចទេ!

ក៖
ចុះលោកយាយកាលពីរតូចនឹងមកលោកយាយមានធ្លាប់មានក្តីស្រម៉ៃថានៅពេលដែលលោកយាយធំឡើងនឹងលោកយាយចង់ធ្វើអីដែរឬទេ?

ខ៖ អត់ទេអត់ដែលបានគិតថាចង់ធ្វើអីទេ ស្រលាញ់តែឪពុកនឹង!

ក៖ អូ......

ខ៖ អត់ដែលបានដឹងថាគិតពីខ្លួនឯងពីអីនឹងអត់ អត់ចេះគិតអីសោះម៉ងត្បិតយើងក្មេងពីដើមយើងល្ងង់ណាស់(មានសំលេងរំខានពីខាងក្រៅ)
អើយើងវាល្ងង់យើងវាអត់ចេះអីណាស់ដឹងតែថាយើងអាយុ១២ឆ្នាំ
១៣ឆ្នាំនឹងតិចៗគ្រាប់ផ្លោងតិចៗនឹងរត់ចូលត្រង់សេគ្មានទៅគិតអីចេញទេកូនអើយ!

ក៖ អញ្ចឹង??

ខ៖ អឺម! ចុះបើគ្រាប់ផ្លោងវាបន្តក់មកនោះ!

ក៖
លោកយាយហើយចុះដូចជាបទចំរៀងបទអីនឹងលោកយាយចូលចិត្តស្តាប់ដែរឬទេលោកយាយ?

ខ៖
ស្តាប់....ស្តាប់នឹងចេះតែស្តាប់ហើយប៉ុន្តែដូចថាយាយមិនសូវជាចូលចិត្តស្តាប់អីប៉ុន្មានទេចៅល្មមៗអីនឹងឯង
ខ្ញុំដូចថាយើងវាមានរឿងដែលពិបាកនឹងច្រើនពេកមិនសូវជាចង់ស្តាប់ប៉ុន្មានទេ!

ក៖ លោកយាយស្តាប់បទអីគេដែរលោកយាយកាលនឹង?

ខ៖ ចាស??

ក៖ បទចំរៀងអីគេដែរលោកយាយ?.....

ខ៖ ទូកទៅបាត់ហើយ? (លោកយាយសួរលោកតា)!

គ៖ ទៅបាត់ហើយ(លោកតាឆ្លើយនឹងលោកយាយ)!

ខ៖ ស្តាប់មិនបានទេកូន!

ក៖
បទចំរៀងអីដែលធ្វើអោយលោកយាយចូលចិត្តស្តាប់ជាងគេណាស់លោកយាយកាលនឹងណាស់?

ខ៖ អឹម! រកនឹកអត់ឃើញទេកូន!

ក៖ អត់ចាំទេហ៎លោកយាយ?

ខ៖ អត់ចាំទេកូន!

ក៖ (សើច) ចុះអឺ.....

ខ៖ (សើច) លឺតែបទណាដែលពិរោះបទស្តាប់បទនឹងទៅ!

ក៖ ចុះអឺ.....កាលពីនៅក្មេងៗនឹងលោកយាយចូលចិត្តលេងល្បែងអីគេដែរ?

គ៖ ហើយ!! នៅពីកាលជំនាន់នឹងនោះទៅមានរបស់អីលេងដូចក្មេងសម័យទេ! (សំលេងរបស់លោកតាប្តីរបស់លោកយាយ)!

ខ៖ (សើច)!

ក៖ កាលពីជំនាន់កូនក្មេងជំនាន់មុនណាស់លោកយាយចូលចិត្តលេងអីគេដែរ?

ខ៖ មានស្អីទេ មានតែរាំវង់!

ក៖ អូ.....ចូលចិត្តលេងរាំវង់!

ខ៖ នឹងហើយ!

កៈ ហើយទៅចូលចិត្តលេងល្បែងអីគេដែរលោកយាយ?

ខៈ ល្បែងចូលចិត្តតែលេងបាយឡុកបាយឡនឹង អស់ហើយមានប៉ុណ្ណឹង(សើច)!

កៈ (សើច)!

កៈ កាលនៅពីតូចៗនឹងមានតែលេងបាយឡុកបាយឡនឹងមានមានលេងស្អីទេ!

កៈ ចាសៗលោកយាយ! ចាសអញ្ចឹងលោកយាយជាចុងក្រោយលោកយាយមានពាក្យពេចន៍អីដើម្បីផ្តាំផ្ញើរទៅដល់អ្នកដែលបានស្តាប់សំលេងរបស់លោកយាយជាពិសេសទៅដល់កូនចៅរបស់លោកយាយអោយគេបានដឹងអំពីជីវិតហើយនឹងការនិយាយរបស់លោកយាយនៅថ្ងៃនឹងអញ្ចឹងណាស់!

ខៈ (សើច) ខ្ញុំសូមផ្តាំផ្ញើរថាកុំអោយមាន អាវែងនែ(ភាសាតំបន់) ធ្វើអោយឪពុកម្តាយពិបាកចិត្ត!

កៈ ចាសលោកយាយ!

ខៈ បើមិនបានអីហុចទៅគាត់ទេកុំអោយតែធ្វើអីអោយគាត់ពិបាកចិត្តទៅបានហើយ ឪពុកម្តាយទូទៅទាំងអស់គ្នានឹងស្រលាញ់កូនណាស់ ចាសខ្ញុំផ្តាំផ្ញើរកុំអោយកូនៗនឹងធ្វើបាបម៉ែឪ អោយចេះជួយអោយចេះស្រលាញ់ម៉ែឪអោយដឹងថាម៉ែឪនឹងស្រលាញ់កូនៗនឹងប៉ុន្នារ?

កៈ ចាសលោកយាយ!

ខៈ ចាសហើយកូនបើមិនបានថាស្រលាញ់ទាំងអស់ក៏ត្រឹមតែពាក់កណ្តាលឬក៏បន្តិចបន្តួចនឹងអោយគាត់បានអស់ចិត្តផងតែប៉ុណ្ណឹង!

កៈ ចាសៗលោកយាយ! អរគុណច្រើនសំរាប់ថ្ងៃនេះដែលបានចំណាយពេលណាស់លោកយាយ!

ខៈ ចាស!